**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា**
**ការិយាល័យតំណាងក្រសួងពាណិជ្ជកម្ម ប្រចាំ**
**រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស អូរនាង ប៉ោយប៉ែត**
លេខ:..002/14.......រតសពប

បន្ទាយមានជ័យ, ថ្ងៃទី 25 ខែ ធ្នូ ឆ្នាំ ២០១៤

**សូមគោរពជូន**
**ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ** : របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ ២០១៤ របស់តំណាងក្រសួងពាណិជ្ជកម្ម ប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស អូរនាង ប៉ោយប៉ែត ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** មេត្តាជ្រាបដូចខាងក្រោម ៖

**I- ស្ថានភាពក្រុមហ៊ុន-រោងចក្រក្នុងតំបន់សេដ្ឋកិច្ចពិសេស អូរនាង ប៉ោយប៉ែត ៖**

- តំបន់សេដ្ឋកិច្ចពិសេស អូរនាង ប៉ោយប៉ែត មានក្រុមហ៊ុន-រោងចក្រចំនួន ០៥
- មានផ្ទៃដីវិនិយោគរបស់តំបន់ សរុបចំនួន ៣៨០ហិកតា

ក្នុងចំណោមក្រុមហ៊ុន-រោងចក្រទាំងអស់ខាងលើ រួមមានសកម្មភាពដូចខាងក្រោម ៖

+ចំនួន០២ ក្រុមហ៊ុន-រោងចក្រ កំពុងមានសកម្មភាពផលិត និងនាំចេញ គឺ ៖

1- រោងចក្រ CAMPACK Co., Ltd. ផលិតប្រអប់វេចខ្ចប់គ្រឿងអលង្ការ ជាក្រុមហ៊ុន-រោងចក្រដែលមានកំណើតដើមមកពីប្រទេសថៃឡង់ដ៍ ហើយការផលិតបានផលិតផល គឺគាត់នាំចេញទៅលក់នៅប្រទេសដើមរបស់គាត់តែប៉ុណ្ណោះ ដូច្នេះគាត់ពុំត្រូវការសុំ C/O ដែលចេញដោយរដ្ឋបាលប្រចាំតំបន់នោះឡើយ ។

2- រោងចក្រ Hi-Tech Apparel (Cambodia) Co., Ltd. ផលិតសម្លៀកបំពាក់កីឡាសម្រាប់នាំចេញ ។

+ ចំនួន ០១ ក្រុមហ៊ុន-រោងចក្រ កំពុងជ្រើសរើស និងហ្វឹកហ្វឺនកម្មករ ៖

*រោងចក្រ ML Intermate Apparel (Cambodia) Co., Ltd. បានសាងសង់ បំពាក់ម៉ាស៊ីន រួចរាល់ហើយ កំពុងជ្រើសរើស និងហ្វឹកហ្វឺនកម្មករបានប្រមាណជា ៩០នាក់ រួចហើយ។

+ ចំនួន ០២ ក្រុមហ៊ុន-រោងចក្រ កំពុងសិក្សាគម្រោងប្លង់ និងចាក់ដីពង្រាបទីតាំង គឺ ៖

*រោងចក្រ SIMMER Inter Co., Ltd. ផលិត និងកែច្នៃគ្រឿងអលង្ការ

*រោងចក្រ Wireform Precision Parts Co., Ltd. ផលិតផ្លាស្ទិក

**II- តារាងផ្តល់ C/O នាំចេញទៅតាមទីផ្សារសំខាន់ៗ ៖**

**-សម្រាប់ខែ ០៦-០៧/២០១៤ ៖**

| ល.រ | ទិសដៅនាំចេញ | ទម្រង់ C/O | ចំនួន C/O | | ផ្សេងៗ |
|---|---|---|---|---|---|
| | | | ខែមិថុនា២០១៤ | ខែកក្កដា២០១៤ | |
| ១ | ផ្សារសហរដ្ឋអាមេរិក | - | - | - | |
| ២ | ទីផ្សារសហគមន៍អឺរ៉ុប | A (EU) | 6 | 4 | |
| ៣ | ទីផ្សារក្រៅសហគមន៍អឺរ៉ុប | - | - | - | |
| ៤ | ទីផ្សារទ្វីបអាហ្វ្រិក | - | - | - | |
| ៥ | ទីផ្សារអាស៊ី និងអូសេអានី | - | - | - | |

**-សម្រាប់ខែ ១០-១១/២០១៤ ៖**

| ល.រ | ទិសដៅនាំចេញ | ទម្រង់ C/O | ចំនួន C/O | | ផ្សេងៗ |
|---|---|---|---|---|---|
| | | | ខែតុលា២០១៤ | ខែវិច្ឆិកា២០១៤ | |
| ១ | ផ្សារសហរដ្ឋអាមេរិក | - | - | - | |
| ២ | ទីផ្សារសហគមន៍អឺរ៉ុប | A (EU) | 2 | - | |
| ៣ | ទីផ្សារក្រៅសហគមន៍អឺរ៉ុប | - | - | - | |
| ៤ | ទីផ្សារទ្វីបអាហ្វ្រិក | - | - | - | |
| ៥ | ទីផ្សារអាស៊ី និងអូសេអានី | D | - | 1 | |

**III- តារាងចំណូលថវិកាពីការគ្រប់គ្រងការនាំចេញ និងសោហ៊ុយរដ្ឋបាល ៖**

**-សម្រាប់ខែ ០៦-០៧/២០១៤ ៖**

| ល.រ | ADM & EMF | ទឹកប្រាក់ | | សរុប | ផ្សេងៗ |
|---|---|---|---|---|---|
| | | ខែមិថុនា២០១៤ | ខែកក្កដា២០១៤ | | |
| ១ | ADM (USD) | 48 | 32 | 80 | |
| ២ | EMF (USD) | 250.348 | 1,487.128 | 1,737.476 | |

**-សម្រាប់ខែ ១០-១១/២០១៤ ៖**

| ល.រ | ADM & EMF | ទឹកប្រាក់ | | សរុប | ផ្សេងៗ |
|---|---|---|---|---|---|
| | | ខែតុលា២០១៤ | ខែវិច្ឆិកា២០១៤ | | |
| ១ | ADM (USD) | 16 | 8 | 24 | |
| ២ | EMF (USD) | 896.232 | 226.691 | 1,122.923 | |

**IV- ចំនួនបុគ្គលិក-កម្មករ ដែលកំពុងបម្រើការក្នុងរោងចក្រ ៖**

ចំនួនបុគ្គលិក-កម្មករ ដែលកំពុងបម្រើការក្នុងរោងចក្រ បច្ចុប្បន្នមានប្រមាណជា ១.២០០នាក់ៗ ក្នុងនោះខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនផងដែរថា តំបន់សេដ្ឋកិច្ចពិសេស អូរនាង ប៉ោយប៉ែត ជាតំបន់មួយ ដែលជាប់ជាមួយព្រំដែនប្រទេសថៃ ដូច្នេះកម្មករមិនសូវបានបម្រើការឲ្យបានជាប់លាប់នោះទេ ដោយពួក

គាត់មួយចំនួនតែងតែធ្វើចំណាកស្រុកទៅមក ជាហេតុបណ្តាលឲ្យម្ចាស់រោងចក្រជួបកាលំបាកលើបញ្ហាជ្រើសរើសកម្មករដើម្បីបម្រើការក្នុងរោងចក្ររបស់គាត់ ។

**V- អំពីបញ្ហាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ចូលទៅកាន់តំបន់សេដ្ឋកិច្ចពិសេស ៖**

ទីតាំងតំបន់សេដ្ឋកិច្ចពិសេស អូរនាង ប៉ោយប៉ែត គឺត្រូវធ្វើដំណើរពីទីរួមខេត្តបន្ទាយមានជ័យតាមបណ្តោយផ្លូវជាតិលេខ ៥ ឆ្ពោះទៅកាន់ក្រុងប៉ោយប៉ែត ប៉ុន្តែទីតាំងរបស់តំបន់ ត្រូវបត់ចុះស្តាំដៃត្រង់ចំណុចភូមិកូនដំរី (មានចម្ងាយប្រមាណជា ១២ គីឡូម៉ែត្រទៀត ទើបដល់ក្រុងប៉ោយប៉ែត) នៅប៉ែកខាងជើង ដែលមានចម្ងាយផ្លូវចូលប្រហែលជា ៨ គីឡូម៉ែត្រ ទើបចូលដល់ក្នុងតំបន់ ។ លើចម្ងាយផ្លូវចូលនេះគឺមានការលំបាកខ្លាំងក្នុងរដូវវស្សា ហើយជាមូលហេតុមួយដែលធ្វើឲ្យក្រុមហ៊ុនដែលមានបំណងចង់ចូលទៅវិនិយោគរោងចក្រនៅក្នុងតំបន់មានការអល់អែកយ៉ាងខ្លាំង ដោយសារហេដ្ឋារចនាសម្ព័ន្ធផ្លូវចូលនោះ។ ហេតុនេះហើយ ក្នុងអំឡុងខែ ០៧-២០១៤ កន្លងមកសាមីក្រុមហ៊ុនម្ចាស់តំបន់ (CHHAY CHHAY INVESTMENT Co., Ltd.) បានស្នើសុំការអនុញ្ញាតពីអាជ្ញាធរខេត្ត ដោយប្រើប្រាស់ធនធានរបស់ខ្លួន ដើម្បីកសាងផ្លូវនោះឲ្យប្រសើរឡើង ។ ប៉ុន្តែក្នុងដំណាក់កាលដែលកំពុងឈូសឆាយ និងចាក់ពង្រាបគ្រួសក្រហម គឺមានក្រុមហ៊ុនមួយរបស់ចិនបានមកប្រាប់ថាមិនចាំបាច់ម្ចាស់តំបន់ធ្វើទេ ព្រោះផ្លូវមួយកំណាត់ខ្សែនេះ ជាភារកិច្ចរបស់ក្រុមហ៊ុនគាត់ជាអ្នកធ្វើក្នុងពេលដ៏ខ្លីខាងមុខនេះ។ រហូតមកដល់ពេលនេះមិនទាន់ឃើញក្រុមហ៊ុនចិនដែលបានមកធានាអះអាងនោះចាប់ផ្តើមធ្វើអ្វីទាំងអស់ (នេះជាបញ្ហាដែលពិបាកធ្វើការ ទាក់ទាញអ្នកវិនិយោគចូលក្នុងតំបន់) ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម**ឯកឧត្តមទេសរដ្ឋមន្ត្រី**មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

**មន្ត្រីតំណាងក្រសួងពាណិជ្ជកម្ម**
**អនុប្រធាននាយកដ្ឋាន**

**ឡុង សោភ័ណ**

**<u>ចម្លងជូន:</u>**

-ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេស
-អគ្គនាយកដ្ឋានសេវាកម្ម
-អគ្គនាយកដ្ឋានគយ និងរដ្ឋាករ
-អគ្គនាយកដ្ឋានកាំកុងត្រូល
-នាយកដ្ឋាននាំចេញ នាំចូល
-នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានក្រសួងពាណិជ្ជកម្ម
-ឯកសារ-កាលប្បវត្តិ